# បម្រែបម្រួលសំណេរពាក្យ «សោយ» (ភាគ១)

នៅក្នុងការសិក្សាអំពីភាសា យើងអាចពិនិត្យតាមការសិក្សាដោយផ្អែកលើអ័ក្សសមកាល (Synchrony) និងតាមអ័ក្សវិសមកាល (Diachrony)។ អ័ក្សសមកាល ផ្ដោតការយកចិត្តទុកដាក់លើការសិក្សាភាសាក្នុងពេលជាក់លាក់ណាមួយ ជាពិសេស គឺពេលបច្ចុប្បន្ន ដោយមិនគិតលើកត្តាប្រវត្តិឬអតីតកាល។ ចំណែកឯ អ័ក្សវិសមកាល ផ្ដោតលើការវិវត្តឬអភិវឌ្ឍរបស់ភាសាតាមរយៈកាលប្រវត្តិ។ វិធីសាស្ត្រនេះ គេច្រើនប្រើនៅក្នុងការសិក្សាភាសាវិទ្យាប្រវត្តិ (Historical Linguistics)។ ភាសា រមែងមានការប្រែប្រួលជានិច្ច។ ភាសាមានបម្រែបម្រួលលើសូរនិងសទ្ទតា វចនសព្ទ សំណេរនិងអក្ខរាវិរុទ្ធ ន័យ និងសម្ព័ន្ធជាដើម។ នៅក្នុងការសិក្សា សង្គមភាសាវិទ្យា គេពិនិត្យការវិវត្តភាសាតាមរយៈទិស៣គឺ តាមរយៈកាល តាមរយៈតំបន់ និងតាមរយៈក្រុម។[១] ការពិនិត្យតាមរយៈកាលនេះហើយដែលយើងអាចសិក្សាផ្អែកលើអ័ក្សសមកាល ឬវិសមកាល។ នៅក្នុងអត្ថបទនេះ នឹងពិនិត្យលើបម្រែបម្រួលសំណេរពាក្យ «សោយ» ដោយផ្អែកលើការសិក្សាតាមអ័ក្សវិសមកាល។

តាមរយៈឯកសារសិលាចារឹកភាសាខ្មែរ យើងឃើញពាក្យ «សោយ» កាលពីសម័យអង្គរមានសំណេរជា «ស្វយ៑» និង «ស្វយ» ដែលលេចឡើងក្នុងអត្ថបទយ៉ាងហោចណាស់ចំនួន៥៣ដង ដែលកាលមុន លោក ហ្វីលីព ជេន្នើរ រកឃើញត្រឹមតែ៤៧ដងប៉ុណ្ណោះ។ ចំនួននេះនឹងកើនឡើងបន្តទៅទៀត អាស្រ័យនឹងសិលាចារឹកដែលរកឃើញជាបន្តបន្ទាប់។ នៅសម័យមុនអង្គរ យើងពុំប្រទះឃើញពាក្យនេះឡើយ។ ប៉ុន្តែយើងអាចសន្និដ្ឋានបានថា នៅសម័យមុនអង្គរ ក៏ទំនងជាមានសំណេរជា «*ស្វយ៑» ដែលជាសំណេរបន្សល់មកដល់សម័យអង្គរ។ ការសន្និដ្ឋាននេះ ផ្អែកលើភស្តុតាងពាក្យ «សំហ្វយ៑» ដែលមាននៅក្នុងសិលាចារឹកថ្មគ្រែ K.១៣៧១ ជាសិលាចារឹកនៅចន្លោះអន្តរកាលរវាងសម័យមុនអង្គរនិងសម័យអង្គរ។[២] បើយើងមើលមកសម័យកណ្ដាល សំណេរពាក្យនេះមានច្រើនរបៀបដូចជា៖ ស្វោយ ស្វោ្យ ស្វោយ្យ និងសោយ។ សំណេរពាក្យ «ស្វោ្យ» នេះ

---

[១] ព្រំ ម៉ល់ ២០១៣: ១៥។

[២] ហ៊ុន ឈុនតេង ២០១៨:១២-១៨។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

នៅបន្តប្រើរហូតមកដល់រាជ្យព្រះបាទស៊ីសុវត្ថិ ដូចមានឃើញនៅតាមចារឹកថ្ម(ស៊ីម៉ង់)នៅតាមចេតិយវត្តភ្នំ និងភ្នំព្រះរាជទ្រព្យ។ នៅក្នុងអត្ថបទទស្សនាវដ្ដីកម្ពុជសុរិយាដំបូងៗ ក៏នៅប្រើពាក្យ «ស្វោយ» នេះដែរ។ លុះមកដល់គ្រាមានវចនានុក្រមខ្មែរ ដែលដើរតួយ៉ាងសំខាន់ក្នុងការកំណត់អក្ខរាវិរុទ្ធផ្លូវការរបស់សំណេរពាក្យនេះ សរសេរជា «សោយ» ផង និង «ស្វោយ» ផង ប៉ុន្តែបច្ចុប្បន្ន យើងប្រើតែសំណេរ «សោយ» តែមួយប៉ុណ្ណោះ។

នៅក្នុងវចនានុក្រមខ្មែរ ក៏បានបញ្ជាក់ផងដែរថា ពាក្យ «សោយ» នេះ ពីបុរាណប្រើជា «ស្វោយ» ចំណែកឯសៀមប្រើជា «ស្វេយ» (เสวย) អានថា «ស្វឺយ»។ ចំណែកឯពាក្យ «ស្វោយ» នៅក្នុងវចនានុក្រមខ្មែរ បញ្ជាក់ពីប្រភពពាក្យនេះថាមកពីពាក្យបាលីថា «សេវ» ឬ «សេវយ» ដែលត្រូវនឹងពាក្យសំស្ក្រឹតថា «សេវិ» មានន័យថាសេព។ បន្ថែមពីនេះ វចនានុក្រមនៅតែដាក់ប្រភពពាក្យសៀមមកជាមួយដែរ។ យើងពុំយល់ពីមូលហេតុច្បាស់លាស់ ដែលវចនានុក្រមខ្មែរបានដាក់ក្នុងចំណុចពន្យល់ប្រភពពាក្យ ដោយប្រាប់អំពីពាក្យសៀមនោះឡើយ។ យ៉ាងនេះក្ដី យើងអាចយល់បានយ៉ាងច្បាស់តាមភស្តុតាងសិលាចារឹកថាពាក្យសៀម «เสวย» ជាពាក្យខ្ចីពីខ្មែរបុរាណ «ស្វយិ» ឬ «ស្វយ» យ៉ាងប្រាកដ ហើយក៏ពុំសមជាពាក្យមានប្រភពមកពីបាលីផងដែរ។ ខាងក្រោមនេះ គឺជាដំណាកស្រង់ឃ្លាមានពាក្យ «ស្វយ» ក្នុងសិលាចារឹកសម័យអង្គរ ៖

- ***វយិអ្នកតបំបាតិធម៌នេះគេស្វយិទោមតគិ*** (K.៣៣៖ ប.៣៥-៣៦) = វីអ្នកដែលបំបាត់បុណ្យនេះ អ្នកនោះ(ត្រូវ)សោយទោស។
- ***វិតបរិបាលនស្វយវិភវ*** (K.១៣៩ ផ្ទាំង២៖ បន្ទាត់១៧) = វិ(អ្នក)ដែលថែរក្សា (សិលាចារឹកនេះ នឹង) សោយនូវវិភព(គឺទ្រព្យសម្បត្តិ សេចក្ដីចម្រើន...)។
- ***ធូលិវ្រះបាទធូលិជេងវ្រះកម្រតេងអញ្ស្រីជយវម៌្មទេវ តស្វយវ្រះធម៌្មរាជ្យនុឯកនវអម្ពគក*** (K.១៧៥ ផ្ទាំងខាងត្បូង ៖ បន្ទាត់១៥) = ធូលីព្រះបាទធូលីជើងព្រះគម្តែងអញស្រីជ័យវម៌្មទេវសោយព្រះធម្មរាជ្យនាមហាសករាជ(ឆ្នាំ)៨៩១។
- ***នៅវ្កុលនុគិម្យនុអ្នកិសញ្ជកិតគ្រទ្វារវ្ទ័បរិបាលនធម៌្មនេះ ស្វយិផលសមភាគនុវ្រះកម្រតេងអញ្ស្រីយោគីឝ្វរបណ្ឌិត*** (K.២១១៖ បន្ទាត់៥) = នៅបងប្អូន សិស្ស និងអ្នកសញ្ជកដែលមានសទ្ធាចម្រើននិងថែរក្សាបុណ្យនេះ (សូម)សោយផល

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ស្មើភាគនិងព្រះគម្តែងអញស្រីយោគីសូរបណ្ឌិត។

- **នៅគេតសក្កកល្បនានេះ គេស្វេយិត្រៃត្រឹគនរកយាវតចន្ទ្រាទិត្យមានលេយិ** (K.២១៤ ផ្ទាំង៦ៈ បន្ទាត់១៨-១៩) = នូវអ្នកដែលលួចគ្រឿងវណ្ដាប់បូជានេះ អ្នកនោះសោយនូវនរកសាមសិបពីរជាន់ ដរាបណាព្រះចន្ទ្រនិងព្រះអាទិត្យនៅតែមាន។

នៅក្នុងការប្រែប្រួលពាក្យ/សំណេរពាក្យ ពី «ស្វោយ/ស្វោ្យ» មកជា «សោយ» បានបង្ហាញបម្រែបម្រួលមួយក្នុងភាសាខ្មែរ ដែលតួជើងវ ឬសូរព្យញ្ជនៈ «វ» នៅលំដាប់ទីពីរក្នុងទម្រង់ព្យាង្គ «ពពស» បានធ្លាក់បាត់សូរក្នុងពាក្យ «ស្វោយ ធ្វើ អ្វី ថ្វី» ដែលនាំឱ្យពាក្យនោះក្លាយជា «សោយ[៣] អី ថី ធើ[៤]»។ មូលហេតុដែលនាំឱ្យពាក្យទាំងបួននេះ បាត់សូរ «វ» ខណៈពាក្យជាច្រើនទៀតដែលមានសូរនិងព្យញ្ជនៈ «វ» នៅលំដាប់ទីពីរ ក្នុងទម្រង់ព្យាង្គ «ពពស» តែពុំបាត់បង់សូរនោះ ជាកម្មវត្ថុដែលគួរពិនិត្យនិងស្រាវជ្រាវបន្ត។ នៅទីនេះ ខ្ញុំដាក់ការសង្ស័យថា «សោយ អី ថី ធើ» អាចជាពាក្យឫសដែលកម្ចាយដោយផ្នត់ដែក [-វ-]។ ចំណុចនេះ អាចដូចករណីពាក្យ ស្ទ ស្ទុក ស្ទាប់... ដែលអ្នកស្រុកខ្លះនិយាយជា ឡ ឡុក ឡាប់ និងអ្នកស្រាវជ្រាវខ្លះពន្យល់ថាជាធ្លាក់ចុះឬបាត់បង់សូរដើមព្យាង្គ។ ប៉ុន្តែយើងអាចពិនិត្យឃើញថាពាក្យទាំងនោះជាពាក្យឫសទៅវិញ ដូចករណីខ្មែរប្រើពាក្យ «បាយឡុកបាយឡ»។ ឬពាក្យទាំងបួននោះ អាចជាពាក្យមកពីភាសាដទៃ? ប្រសិនបើពាក្យ «ស្វេយិ» មានពាក្យឫសជា «សេយិ» ដែលអាចវិវត្តមកជាសូរថា «ស៊ើយ» នោះអាចនាំឱ្យយើងគិតដល់ពាក្យ «xơi» ក្នុងភាសាវៀតណាម ដែលមានន័យថា «ហូប ផឹក ស៊ី...» ដ្បិតពាក្យខ្មែរក៏មានទំនាក់ទំនងជាមួយពាក្យក្នុងស្រទាប់ភាសាវៀតណាមបុរាណមួយចំនួនផងដែរ។[៥]

(នៅមានត)

---

[៣] ក្នុងសំណេរនិងសម្ដីផ្លូវការ។

[៤] ពាក្យទាំងបីនេះនៅក្នុងភាសាខ្មែរ ហាក់ចាត់ទុកជាសំណេរនិងសម្ដីមិនផ្លូវការ ទោះបីជាក្នុងវចនានុក្រមខ្មែរ មានពាក្យ «ថី?» និង «អី?» ដែលពន្យល់ថាមានន័យដូចពាក្យ ថ្វី និង អ្វី ដែលប្រើក្នុងទម្រង់សំណួរក៏ដោយ។ ចំណែកឯពាក្យ «ធើ» ពុំមានសំណេរក្នុងវចនានុក្រមឡើយ។ ពាក្យ ធើ អី និង ថី មនុស្សខ្មែរយល់ថាពាក្យទាំងនេះ មានន័យពុំសមរម្យ ឬ ទ្រគោះ។

[៥] សូមអានបន្ថែមៈ https://ams.com.kh/khmercivilization/detail/20098 ។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

## តារាងសម្រង់ពាក្យ

| សំណេរពាក្យបុរាណ | ស្រង់ចេញពីសិលាចារឹក |
| --- | --- |
| ស្វេយ៑ ស្វេយ | K.33: 35; K.139: B 17; K.175: S15 & W10; K.194: A10, 13 & 27; K.211: 5; K.214: B18; K.219: 2; K.230: C3; K.235: D4, 64 & 81; K.277: S14 & 15; K.292 (x4); K.324: S14; K.327: S15; K.330: S18; K.331: S20; K.342: W18; K.350: N3, 5 & 6; K.352: N39 & 43; K.413: A13 & B10; K.444: A4 & C13; K.467: 8; K.523: C22 & 26; K.583: B7; K.598: B2; K.697: B3, 26 & 27; K.705: 10 & 11; K.817: 15, 17 & 19; K.868: A3 & B7; K.956: 48; K.1065: 4 & 5 |
| ស្វោយ ស្វោ្យ | K.261: A20, K. 285: 17 & 21; K.301: 8, 18 (x2), 25 & 44; K.465: 12 & 15 |
| ស្វោយ្យ | IMA 13:29 |
| សោយ | K.261: B26, D26, E12 & E15; K.301: 46; K.303 No10: 12 |
| សំហ្វេយ៑ | K.1371 |
| សំវេយ៑ | K.99: N26; K.349: 15 |
| សង្វេយ | K.143: A10; K.299: 5; K.315: N12; K.318: N13; K.353: S33; K.702: B12; K.1073 |
| សំង្វេយ | K.99: S22; |

## ឯកសារយោង


ព្រំ ម៉ល់

២០១៣. មូលដ្ឋាននៃសង្គមភាសាវិទ្យា (ដោយរៀបចំថ្មីនិងបន្ថែមបន្ថែម), ផ្សាយចេញលើកទី២, ភ្នំពេញ។

ហ៊ុន ឈុនតេង

២០១៨. "សិលាចារឹកមកពីភូមិថ្មគ្រែ K.១៣៧១", ក្នុងកម្ពុជសុរិយា លេខ២, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។


អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## បញ្ជីរូបភាព




ពាក្យស្រង់ចេញពីសំណៅផ្តិតសិលាចារឹក



សំណេរពាក្យ «ស្ញាយ» ក្នុងសិលាចារឹកវត្តអង្គា (រូបថត៖ EFEO)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង